EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០៦៤៧ អាក.១៤ អអក

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីនៅស្រុកស្ទោង ខេត្តកំពង់ធំ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ អ៊ុង ហុកស៊ីន សេវាករឈ្មោះ ថៃ សុធន និងសេវាករឈ្មោះ ឃុន ណៃហៀក

យោង៖ កំណត់ហេតុប្រជុំនៅសាលាខេត្តកំពង់ធំ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤។

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជំរាបជូនសាធារណជន**អ្នកប្រើប្រាស់អគ្គិសនីក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី** របស់សេវាករឈ្មោះ អ៊ុង ហុកស៊ីន, សេវាករ ថៃ សុធន និងសេវាករឈ្មោះ ឃុន ណៃហៀក នៅស្រុកស្ទោង ខេត្តកំពង់ធំ មេត្តាជ្រាបថា លើមូលដ្ឋាននៃយុទ្ធសាស្រ្តញប្រកពអគ្គិសនីចេញពីអនុស្ថានីយ ដែលមានថ្លៃសមរម្យ កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាបានសម្រេចអនុញ្ញាតឲ្យ **ក្រុមហ៊ុន ប៊ី ធី ស៊ី ផៅវ័រ ឌីវែឡុបមិន** ធ្វើការវិនិយោគសាងសង់ខ្សែពង្រីកបណ្តាញបញ្ជូនរង ដើម្បីបញ្ជូនអគ្គិសនីចេញពីអនុស្ថានីយក្រុងកំពង់ចាម ទៅផ្គត់ផ្គង់ឲ្យតំបន់ចែកចាយមួយចំនួនទៀត បន្តពីក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ ព្រមទាំងស្រុកមួយចំនួនទៀត ក្នុងខេត្តកំពង់ធំ ជាបន្តបន្ទាប់ ដើម្បីបន្ធូរបន្ថយអត្រាថ្លៃលក់បច្ចុប្បន្នឲ្យថយចុះបន្តិចម្តងៗ សម្រួលដល់ប្រជាពលរដ្ឋអ្នកប្រើប្រាស់។ បន្ទាប់ពីបានធ្វើការពិនិត្យ វិភាគថ្លៃដើមអគ្គិសនីបច្ចុប្បន្នរបស់ក្រុមហ៊ុនបញ្ជូនរង និងសេវាករទាំង៣ ខាងលើ និងយោងតាមស្មារតីសម្រេចនៃអង្គប្រជុំពិភាក្សានៅសាលាខេត្តកំពង់ធំ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចបញ្ចុះថ្លៃអគ្គិសនី នៅតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ អ៊ុង ហុកស៊ីន, សេវាករ ថៃ សុធន និងសេវាករឈ្មោះ ឃុន ណៃហៀក **ចុះពីអត្រាថ្លៃលក់ជាង ៣,០០០ រៀល/គីឡូវ៉ាត់ម៉ោង មក ១,៦០០ រៀល/គីឡូវ៉ាត់ម៉ោង អនុវត្ត គិតពីពេលតភ្ជាប់យកប្រភពថាមពលប្រើប្រាស់ពីក្រុមហ៊ុន ប៊ីធីស៊ី ផៅវ័រ ឌីវែឡុបមិន នៅខែធ្នូ ឆ្នាំ២០១៤ និងបញ្ចុះមក ១,៥០០ រៀល/គីឡូវ៉ាត់ម៉ោង អនុវត្តថាមពលប្រើប្រាស់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៥។**

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនី អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ អ៊ុង ហុកស៊ីន, សេវាករ ថៃ សុធន និងសេវាករឈ្មោះ ឃុន ណៃហៀក មេត្តាជ្រាបជាព័ត៌មាន ដោយអនុគ្រោះ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

ចម្លងជូន
- ក្រសួងរ៉ែ និងថាមពល
- សាលាខេត្តកំពង់ធំ
- មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ
- សាលាស្រុកស្ទោង
- សាលាឃុំពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"
- ក្រុមហ៊ុន ប៊ី វី ស៊ី ផៅវ៉ ឌីវ៉ែឡុបមិន
- សេវាករ អ៊ុង ហុកស៊ីន
- សេវាករ ថៃ សុធន
- សេវាករ ឃុន ណៃហៀក

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ